# គោលការណ៍ឯកជនភាពរបស់កម្មវិធី អ៊ីអនកាតម៉ូបាល

## សេចក្តីផ្តើម

នេះគឺជាគោលការណ៍ឯកជនភាពរបស់ កម្មវិធីអ៊ីអនកាតម៉ូបាល សូមធ្វើការពិចារណាដោយប្រុងប្រយ័ត្នមុននឹងអ្នកចាប់ផ្តើមប្រើប្រាស់វា។ នៅពេលដែលលោកអ្នកចូលទៅកាន់ និងប្រើប្រាស់កម្មវិធីនេះ ដោយចុចលើពាក្យ "យល់ព្រម" នោះមានន័យថា លោកអ្នកបានយល់ព្រម និងអនុវត្តតាមខ្លឹមសារ និងលក្ខខណ្ឌរបស់ កម្មវិធីអ៊ីអនកាតម៉ូបាល។ ប្រសិនបើលោកអ្នកមិនយល់ ឬមិនច្បាស់អំពីខ្លឹមសារ និងលក្ខខណ្ឌនេះ សូមទាក់ទងមកកាន់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ដើម្បីសុំសេចក្តីបញ្ជាក់ និងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខ ០២៣ ៩៨៨ ៥៥៥។

### ១). និយមន័យ

- **ធនាគារឯកទេស អ៊ីអន៖** ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- **អ៊ីអនកាត៖** ផលិតផលប័ណ្ណឥណទាន ដែលចេញដោយ ធនាគារឯកទេស អ៊ីអន។
- **ម្ចាស់អ៊ីអនកាត៖** បុគ្គលដែលជាម្ចាស់អ៊ីអនកាត។
- **គណនី៖** គណនីរបស់កម្មវិធី អ៊ីអនកាតម៉ូបាល និង អ៊ីអនកាត នៅក្រោមធនាគារឯកទេស អ៊ីអន។
- **កម្មវិធី៖** កម្មវិធី អ៊ីអនកាតម៉ូបាល លើទូរស័ព្ទស្មាតហ្វូន។
- **ថ្ងៃធ្វើការ៖** ចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ពីម៉ោង ៩ ព្រឹក រហូតដល់ម៉ោង ៦ រសៀល និងដកចេញថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកសាធារណៈ។
- **សេវាកម្មបម្រើអតិថិជន៖** ជាក្រុមការងារផ្តល់សេវាកម្ម ដែលនឹងទទួលបន្ទុក និងធ្វើការដោះស្រាយបញ្ហានានារបស់លោកអ្នកទាក់ទងនឹងការប្រើប្រាស់សេវាកម្មអ៊ីអនកាតម៉ូបាល។
- **កម្រៃសេវា៖** ជាកម្រៃ ដែលអាចត្រូវបានកាត់យកដោយ ធនាគារឯកទេស អ៊ីអន និងដែលមានបញ្ជាក់ក្នុងកម្មវិធីអ៊ីអនកាតម៉ូបាល។
- **ព័ត៌មាន៖** រាល់ព័ត៌មានគណនី ដែលលោកអ្នកបានផ្តល់ឲ្យ ធនាគារឯកទេស អ៊ីអន ដោយរួមបញ្ចូលទាំងព័ត៌មានឯកជន ព័ត៌មានហិរញ្ញវត្ថុ ឬព័ត៌មានដទៃទៀត ទាក់ទងនឹងលោកអ្នក ឬ អាជីវកម្មរបស់លោកអ្នក រួមមានតែមិនកម្រិតត្រឹមព័ត៌មាន ដែលទាក់ទងនឹងដំណើរការទូទាត់ប្រាក់ ការតម្កល់ទុក ឬលក្ខណៈពិសេសផ្សេងទៀតរបស់សេវាកម្មធនាគារឯកទេស អ៊ីអន។ លោកអ្នក ត្រូវទទួលខុសត្រូវដោយខ្លួនផ្ទាល់សម្រាប់ព័ត៌មានរបស់លោកអ្នកនៅពេលដែលធនាគារឯកទេស អ៊ីអន ដើរតួនាទីជាចលករអេកម្មក្នុងការផ្តល់ និងការផ្សព្វផ្សាយព័ត៌មានរបស់លោកអ្នកតាមប្រព័ន្ធអនឡាញ។
- **អាជីវករ៖** បុគ្គលដែលផ្តល់សេវាកម្ម និង/ឬ លក់ទំនិញ ដោយប្រើប្រាស់សេវា អ៊ីអនកាតម៉ូបាល់ ដើម្បីទទួលការទូទាត់។
- **ផលិតផល៖** រាល់ផលិតផល ទំនិញ ឬ សេវាកម្ម ដែលអ្នកទិញធ្វើការជាវ/ទិញ ដោយប្រើប្រាស់សេវាកម្មអ៊ីអនកាតម៉ូបាល។
- **លេខសម្ងាត់៖** លេខសម្ងាត់ទាំង៤ខ្ទង់ ដែលលោកអ្នកប្រើប្រាស់ដើម្បីចូលទៅកាន់ និងធ្វើប្រតិបត្តិការក្នុងកម្មវិធីអ៊ីអនកាតម៉ូបាល លើទូរស័ព្ទស្មាតហ្វូនរបស់លោកអ្នក។
- **ពាក្យសម្ងាត់៖** ការរួមបញ្ចូលនៃតួអក្សរ លេខ និងនិមិត្តសញ្ញាប្រើដើម្បីបង្ហាញពីសិទ្ធិក្នុងការចូលពិនិត្យព័ត៌មាន និងគណនី។
- **របាយការណ៍វិក្កយបត្រ៖** របាយការណ៍ប្រចាំខែ ដែលធនាគារឯកទេស អ៊ីអន ចេញទៅឲ្យម្ចាស់អ៊ីអនកាត ដោយបង្ហាញនូវប្រតិបត្តិការថ្មីៗរបស់អ្នកប្រើប្រាស់ ការទូទាត់អប្បបរមាប្រចាំខែ និង ការទូទាត់គ្រប់ចំនួន។ របាយការណ៍វិក្កយបត្រត្រូវបានចេញជាប្រចាំខែនៅរៀងរាល់ចុងខែនៃវិក្កយបត្រវិលជុំ។

- **QR** កូដ៖ ជាលេខឆ្លើយតបរហ័ស ដែលមានព័ត៌មានរបស់អាជីវករ និងលេខអត្តសញ្ញាណកម្មរបស់អាជីវករ និងអាចអានបានដោយទូរស័ព្ទស្មាតហ្វូនរបស់លោកអ្នក ដើម្បីធ្វើការទូទាត់ទៅឲ្យអាជីវករ។
- **ប្រតិបត្តិការ**៖ រាល់សកម្មភាពដាក់ប្រាក់ ឬដកប្រាក់ ដែលបានធ្វើឡើងដោយអ្នកប្រើប្រាស់កម្មវិធីអ៊ីអនកាតម៉ូបាល។
- **លោកអ្នក**៖ ម្ចាស់គណនី ឬ បុគ្គល ដែលបានចុះឈ្មោះគណនីក្នុងកម្មវិធីអ៊ីអនកាតម៉ូបាល។
- **ជីវមាត្រ**៖ការបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួនផ្ទៀងផ្ទាត់ តាមរយៈការវាស់វែង និងការវិភាគលក្ខណៈខាងក្រៅ ឬ អាកប្បកិរិយាតែមួយគត់ (ដូចជា ស្នាមក្រយៅដៃ មុខ សំឡេង ឬភ្នែក)។

### ២). តើអ្វីទៅជា សេវាកម្មអ៊ីអនកាតម៉ូបាល?

អ៊ីអនកាតម៉ូបាល ជាកម្មវិធីសម្រាប់ស្មាតហ្វូន ឬទូរស័ព្ទដទៃទៀត ដែលអនុញ្ញាតឲ្យទាញយកពីកន្លែងដែលរចនាឡើង ដើម្បីឲ្យម្ចាស់អ៊ីអនកាតប្រើប្រាស់សម្រាប់គ្រប់គ្រងអ៊ីអនកាត ឬធ្វើការទូទាត់ក្រោមស្លាកសញ្ញាអ៊ីអនកាតជំនួសប័ណ្ណប្លាស្ទិក។

### ៣). ការប្រាក់ និង កម្រៃសេវា

គណនីអ៊ីអនកាតម៉ូបាល គឺប្រើក្រោមគណនីប័ណ្ណឥណទាន។ ដូចនេះ ធនាគារឯកទេសអ៊ីអន មិនយកការប្រាក់ ឬកម្រៃសេវា ផ្សេងៗ ពីលោកអ្នកទេ។ រាល់ប្រតិបត្តិការដែលដំណើរការនឹងប្រព្រឹត្តតាមរយៈអ៊ីអនកាត។

### ៤). ការចែករំលែកព័ត៌មានឯកជន

ព័ត៌មានរបស់លោកអ្នក ដែលដំណើរការដោយ ធនាគារឯកទេស អ៊ីអន នឹងត្រូវបានទុកជាព័ត៌មានសម្ងាត់ ប៉ុន្តែ ធនាគារឯកទេស អ៊ីអន អាចផ្តល់ព័ត៌មានទាំងនោះទៅឲ្យភាគី (ទោះក្នុង ឬ ក្រៅប្រទេសរបស់លោកអ្នក) ផ្សេងទៀតដូចខាងក្រោម៖

ក). ចង្កោមក្រុមហ៊ុន របស់ធនាគារឯកទេស អ៊ីអន។

ខ). រាល់ភ្នាក់ងារ ភាគីនៃកិច្ចសន្យា ឬ អ្នកផ្តល់សេវាតតិយជនដែល ធនាគារឯកទេស អ៊ីអន ធ្វើការជាមួយ ក្នុងការផ្តល់សេវាកម្ម អ៊ីអនកាតម៉ូបាល រួមបញ្ចូលទាំងការពារមិនឲ្យមានអំពើល្មើសកើតឡើង ការបញ្ចូលទិន្នន័យ ការគ្រប់គ្រងទិន្នន័យ កម្មវិធីពិសេស ការផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មអតិថិជន សេវាកម្មបច្ចេកវិទ្យា ការផ្តល់ព័ត៌មានជូនដំណឹងទាក់ទងនឹងផលិតផល និងសេវាកម្ម ។

គ). ក្រុមហ៊ុនដែល ធនាគារឯកទេស អ៊ីអន គ្រប់គ្រងការរៀបចំពាណិជ្ជកម្ម រួមបញ្ចូលទាំងអាជីវករ តតិយជន និងក្រុមហ៊ុនដែលជាចង្កោមក្រុមក្រុមហ៊ុនរបស់ ធនាគារឯកទេស អ៊ីអន ។

ឃ). គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ធនាគារដៃគូ ក្រុមហ៊ុនប្រមូលបំណុល និងក្រុមហ៊ុនឥណទាន ។

ង). អ្នកប្រឹក្សាយោបល់ជំនាញ ទីភ្នាក់ងារអនុវត្តច្បាប់ អាជ្ញាធររដ្ឋាភិបាល និងច្បាប់ ឬ អង្គការផ្សេងទៀតដែលធនាគារឯកទេស អ៊ីអន មានកាតព្វកិច្ចចែករំលែកព័ត៌មាន តាមការតម្រូវដោយច្បាប់ បទបញ្ញាតិ ឬ ការរៀបចំខាងពាណិជ្ជកម្ម រួមទាំងការរៀបចំជាមួយបណ្តាញទូទាត់ ឬ

ច). ក្រុមហ៊ុនពាក់ព័ន្ធនឹងការរួមក្រុមហ៊ុនបញ្ចូលគ្នា ការទិញយក ឬប្រតិបត្តិការហិរញ្ញវត្ថុ ជាមួយធនាគារឯកទេស អ៊ីអន ។

### ៥). ព័ត៌មាន

ធនាគារឯកទេស អ៊ីអន នឹងចាត់វិធានការ រួមមានការថែរក្សាផ្នែកបច្ចេកទេស រដ្ឋបាល និងដោយរូបីដើម្បីជួយការពារព័ត៌មានរបស់លោកអ្នកដែលធនាគារឯកទេស អ៊ីអន ទទួលបានពីការបាត់បង់ ការប្រើខុស និងដោយគ្មានការអនុញ្ញាត ការបង្ហាញ ការកែសម្រួល និងការបំផ្លាញ ។

ប្រសិនបើលោកអ្នកមានការបង្ហាញ ឬ ការសង្ស័យអំពីព័ត៌មានរបស់លោកអ្នក គណនី លេខសម្ងាត់ ពាក្យសម្ងាត់ ជីវមាត្រ ឬលក្ខណៈសុវត្ថិភាពផ្សេងទៀត ត្រូវបានបាត់បង់ លួច មិនត្រឹមត្រូវ ប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬ មិនបានយល់ព្រម នោះលោកអ្នកត្រូវបាន

ណែនាំឲ្យធ្វើការផ្លាស់ប្តូរព័ត៌មានរបស់លោកអ្នក និងលេខសម្ងាត់។ លោកអ្នក ត្រូវទាក់ទងមកសេវាកម្មអតិថិជនរបស់យើងខ្ញុំ ដោយមិន ពន្យាពេល ដែលអាចធ្វើឲ្យមានការបាត់បង់ លួច មិនត្រឹមត្រូវប្រើប្រាស់ដោយគ្មានការអនុញ្ញាតនូវព័ត៌មានរបស់លោកអ្នក គណនី លេខសម្ងាត់ ឬ លក្ខណៈសុវត្ថិភាពផ្សេងទៀត ។

ធនាគារឯកទេស អ៊ីអន អាចផ្អាកដំណើរការគណនីរបស់លោកអ្នក ឬ ហាមឃាត់តួនាទីរបស់វា ក្រោមហេតុផលសមរម្យទាក់ទងនឹងសុវត្ថិភាពរបស់គណនី ឬ លក្ខណៈសុវត្ថិភាពផ្សេងទៀត ឬ ប្រសិនបើ ធនាគារឯកទេស អ៊ីអន សង្ស័យដោយហេតុផលថាមានការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬ ដោយទុច្ចរិតលើគណនីរបស់លោកអ្នក ឬ ដោយហេតុថាមានការប៉ះពាល់ដល់លក្ខណៈសុវត្ថិភាពរបស់វា។ ធនាគារឯកទេស អ៊ីអន នឹងជូនដំណឹងជាមុន ឬជាក្រោយ ទៅកាន់លោកអ្នក អំពីការផ្អាកដំណើរការ ឬ ការហាមឃាត់ណាមួយដោយហេតុផលណាមួយ លើកលែងតែការជូនដំណឹងទៅកាន់លោកអ្នកនេះ វាជាអំពើបំពានច្បាប់ ឬ ប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ ធនាគារឯកទេស អ៊ីអន ។ ធនាគារឯកទេស អ៊ីអន នឹងដកហូតការផ្អាក ឬ ការហាមឃាត់ដំណើរការនេះវិញ នៅពេលដែលយើងមានហេតុផលសមរម្យ ដែលបញ្ចប់ការផ្អាក ឬ ការហាមឃាត់ដំណើរការនេះត្រូវបានបញ្ចប់ ។

បន្ថែមលើវិធាននានាខាងលើ ជាពិសេសទាក់ទងនឹងកម្មវិធីអ៊ីអនកាតម៉ូបាល លោកអ្នកត្រូវចាត់វិធានការគ្រប់បែបយ៉ាងដើម្បីឲ្យកម្មវិធីអ៊ីអនកាតម៉ូបាល មានសុវត្ថិភាព និងអាចការពារបានពីការប្រើប្រាស់ដោយទុច្ចរិត និងជាពិសេសៈ

ក). លោកអ្នកមិនត្រូវដាក់លេខសម្ងាត់ ពាក្យសម្ងាត់ជាលេខទូរស័ព្ទស្មាតហ្វូន ឬជាថ្ងៃខែឆ្នាំកំណើត របស់លោកអ្នកឡើយ ។
ខ). លោកអ្នកមិនត្រូវចែករំលែកលេខសម្ងាត់ ពាក្យសម្ងាត់ និងទូរស័ព្ទស្មាតហ្វូនរបស់លោកអ្នក ទៅឲ្យអ្នកដទៃ ។
គ). លោកអ្នកមិនត្រូវសរសេរ ឬ កត់ត្រាលេខសម្ងាត់ ពាក្យសម្ងាត់នៅកន្លែងផ្សេងៗ ដូចជាលើទូរស័ព្ទស្មាតហ្វូន ក្រដាស់ ឬ ប័ណ្ណជាដើម ។
ឃ). លោកអ្នកមិនត្រូវ ឲ្យអ្នកដទៃប្រើប្រាស់គណនីអ៊ីអនកាតម៉ូបាល របស់លោកអ្នក ។
ង). លោកអ្នកត្រូវទុកទូរស័ព្ទស្មាតហ្វូនរបស់លោកអ្នកឲ្យមានសុវត្ថិភាព ឬ
ច). លោកអ្នកត្រូវធ្វើការផ្លាស់ប្តូរលេខសម្ងាត់ ពាក្យសម្ងាត់ជាញឹកញាប់ ។

### ៦). ការជូនដំណឹង និង ការផ្លាស់ប្តូរ

ព័ត៌មាន ឯកសារ និងខ្លឹមសារ ដែលមានក្នុងកម្មវិធីអ៊ីអនកាតម៉ូបាល ឬ គេហទំព័រ អាចត្រូវបានកែប្រែ នៅគ្រប់ពេលវេលា ដោយមិនចាំបាច់ជូនដំណឹងជាមុន។ ធនាគារឯកទេស អ៊ីអន អាចធ្វើការកែប្រែខ្លឹមសារ និងលក្ខខណ្ឌនៅគ្រប់ពេលវេលា ដោយធ្វើបច្ចុប្បន្នភាពកម្មវិធីអ៊ីអនកាតម៉ូបាល។ លោកអ្នកយល់ព្រមត្រួតពិនិត្យនូវរាល់ ខ្លឹមសារ និងលក្ខខណ្ឌអនុវត្តជាប្រចាំ និងយល់ព្រមថា ការប្រើប្រាស់ផ្នែកមួយនៃកម្មវិធីនេះ អាចនឹងត្រូវបានកែប្រែ នៅពេលណាមួយ ។

### ៧). ការប្រមូលព័ត៌មាន

នៅពេលដែលលោកអ្នកចុះឈ្មោះប្រើប្រាស់គណនី និងខណៈពេលដែលលោកអ្នកជាម្ចាស់អ៊ីអនកាត លោកអ្នកយល់ព្រមថា ធនាគារឯកទេស អ៊ីអន អាចធ្វើការប្រមូលព័ត៌មាន ពីលោកអ្នកដូចជាៈ

- រាល់ព័ត៌មាន ដែលលោកអ្នកបានផ្តល់ឲ្យ ធនាគារឯកទេស អ៊ីអន នៅពេលដែលលោកអ្នកចុះឈ្មោះប្រើប្រាស់គណនីថ្មី ឬ បន្ទាប់ពីចុះឈ្មោះទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាពរួច ។
- រាល់ផលិតផល ឬ សេវាកម្ម ដែលលោកអ្នកបានទិញ ។
- ប្រតិបត្តិការមុនៗ ឬ
- កំណត់ត្រានូវរាល់ព័ត៌មាន ឬ បញ្ហានានា ដែលលោកអ្នកបានធ្វើការទាក់ទងមកកាន់ ធនាគារឯកទេស អ៊ីអន

- ធនាគារឯកទេស អ៊ីអន ជាកម្មសិទ្ធិករតែម្នាក់គត់នៃព័ត៌មាន ដែលប្រមូលបានលើសេវាកម្មអ៊ីអនកាតម៉ូបាល។ លើសពីនេះទៅទៀត ធនាគារឯកទេស អ៊ីអន នឹងមិនលក់ ចែករំលែក ឬ ជួលព័ត៌មានទាំងនោះទៅឲ្យបុគ្គលដទៃ តាមគ្រប់រូបភាពក្រៅពីខ្លឹមសារដែលមានចែងក្នុងប្រការ ៤ ខាងលើឡើយ ។

**៨). របៀបដែលធនាគារឯកទេស អ៊ីអន ប្រើប្រាស់ព័ត៌មានដែលប្រមូលបាន**

ធនាគារឯកទេស អ៊ីអន អាចប្រមូលព័ត៌មានពីលោកអ្នក ក្នុងគោលបំណងដូចខាងក្រោម៖

- ដើម្បីចុះឈ្មោះបង្កើតគណនី ។
- ដើម្បីដំណើរការប្រតិបត្តិការ និងធ្វើការជូនដំណឹង អំពីប្រតិបត្តិការរបស់លោកអ្នក ឬ សកម្មភាពក្នុងប្រព័ន្ធរបស់លោកអ្នក ។
- ដើម្បីផ្តល់ជូនលោកអ្នកនូវសេវាកម្មបន្តបន្ទាប់ ។
- ដើម្បីផ្តល់ជូនលោកអ្នកនូវជម្រើសផ្សេងៗ សម្រាប់ស្នើសុំ និងប្រើប្រាស់សេវាកម្មនានា ។
- ដើម្បីយល់អំពីតម្រូវការរបស់លោកអ្នក ។
- ដើម្បីបង្កើត គ្រប់គ្រង និងផ្តល់ជូនសេវាកម្មនានា ដែលឆ្លើយតបនឹងតម្រូវការរបស់លោកអ្នក ។
- ដើម្បីជួយធនាគារឯកទេស អ៊ីអន ធ្វើការកំណត់អត្តសញ្ញាណរបស់លោកអ្នក និងគណនីនានាដែលលោកអ្នកបានកាន់កាប់ក្នុង ធនាគារឯកទេស អ៊ីអន ។
- ដើម្បីធ្វើបច្ចុប្បន្នភាព និងអនុញ្ញាតឲ្យ ធនាគារឯកទេស អ៊ីអន អាចកត់ត្រា អំពីលោកអ្នក និងយល់អំពីតម្រូវការហិរញ្ញវត្ថុរបស់លោកអ្នក ។
- ដើម្បីការពារ និងស្វែងរកអំពើល្មើស ឬ សកម្មភាពឧក្រិដ្ឋនានា ឬដើម្បីគ្រប់គ្រង និងដោះស្រាយរាល់ការបាត់បង់ជាក់ស្តែង ឬ ការប៉ះពាល់ខ្លាំងនានាទាក់ទងនឹងអំពើល្មើស ឬ សកម្មភាពឧក្រិដ្ឋនានា ។
- ដើម្បីបំពេញតម្រូវការផ្នែកច្បាប់និងបទបញ្ជានានាដែល ធនាគារឯកទេស អ៊ីអន ជឿជាក់ថាអនុវត្តចំពោះ ធនាគារឯកទេស អ៊ីអន រួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវរបស់ស្ថាប័នផ្សេងៗ ដែលធនាគារឯកទេស អ៊ីអន ស្ថិតនៅក្រោម ។
- ដើម្បីធ្វើឲ្យប្រសើរ និងធ្វើឲ្យសេវាកម្មអ៊ីអនកាតម៉ូបាល បំពេញតម្រូវការគ្រប់អ្នកប្រើប្រាស់ ។
- ដើម្បីដោះស្រាយរាល់បណ្តឹងរបស់អតិថិជន និង / ឬ
- ដើម្បីផ្សព្វផ្សាយសកម្មភាពពាណិជ្ជកម្មនានា ។

**៩). ច្បាប់គ្រប់គ្រង**

ខ្លឹមសារ និងលក្ខខណ្ឌនេះត្រូវគ្រប់គ្រង និងបកស្រាយស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**១០). ការផ្តល់យោបល់ និងចម្ងល់ផ្សេងៗ**

ធនាគារឯកទេស អ៊ីអន ធ្វើការប្តេជ្ញាចិត្តដើម្បីថែរក្សា និងការពាររាល់ព័ត៌មានដែលប្រមូលបាន និងគ្រប់គ្រងដោយ ធនាគារឯកទេស អ៊ីអន និងរង់ចាំទទួលយកការគាំទ្ររបស់លោកអ្នកជាបន្តបន្ទាប់ ។ ក្នុងករណីដែលមានការផ្តល់យោបល់ ឬ ចម្ងល់ផ្សេងៗទាក់ទងនឹងការការពាររាល់ព័ត៌មានរបស់លោកអ្នក សូមទាក់ទងមកកាន់យើងខ្ញុំ តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៨៨ ៥៥៥ ។